# សេចក្តីថ្លែងការណ៍រួម

# ស្តីពី

# ទម្លាក់បទចោទប្រកាន់ និងដោះលែងអ្នកសារព័ត៌មាន

# លោក មិុច ដារ៉ា ជាបន្ទាន់

ភ្នំពេញ ថ្ងៃទី១ ខែតុលា ឆ្នាំ២០២៤

យើងខ្ញុំជាសហគមន៍ ស្ថាប័នសារព័ត៌មាន និងអង្គការសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោម សូមអំពាវនាវឱ្យមានការដោះលែង អ្នកសារព័ត៌មាន លោក មិុច ដារ៉ា ជាបន្ទាន់ ដែលលោកត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ចោទប្រកាន់ពីបទ "ញុះញង់" និងត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៤ ។

ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញបានសាកសួរលោក ដារ៉ា នៅព្រឹកថ្ងៃអង្គារនេះ ហើយក្រោយមកក៏សម្រេចចោទប្រកាន់លោកពីបទ "ញុះញង់" យោងតាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ចំពោះការបង្ហោះនៅលើបណ្តាញសង្គមរបស់លោក ដែលលោកបានបង្ហោះកាលពីថ្ងៃទី២០ ទី២៣ ទី២៦ ទី២៨ និងទី២៩ ខែកញ្ញាថ្មីៗនេះ ។ ការចោទប្រកាន់នេះ អាចនាំឱ្យលោកជាប់ពន្ធនាគាររហូតដល់ ២ឆ្នាំ ដែលបញ្ជាក់យ៉ាងច្បាស់ពីការព្យាយាមបំបិទសម្លេងអ្នកសារព័ត៌មានដ៏លេចធ្លោរម្នាក់នេះ ដែលជាអ្នកសារព័ត៌មានសកម្មម្នាក់ក្នុងការស្រាវជ្រាវ និងតែងតែអំពាវនាវឱ្យអាជ្ញាធរទទួលខុសត្រូវ យកចិត្តទុកដាក់ ក្នុងករណីរំលោភសិទ្ធិមនុស្សជាច្រើន ។ លោក ដារ៉ា ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តកណ្តាល ។

បើយោងទៅតាមសាក្សី លោក ដារ៉ា ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី៣០ ខែកញ្ញា នៅឯបញ្ជរបង់ប្រាក់ចំណុចស្រុកស្រែអំបិល នៅលើផ្លូវល្បឿនលឿនពីខេត្តព្រះសីហនុ មកកាន់រាជធានីភ្នំពេញ ខណៈ លោកនៅក្នុងរថយន្តជាមួយក្រុមគ្រួសារពេលដែលត្រឡប់មកកាន់រាជធានីភ្នំពេញវិញ ។ រថយន្តក្រុមគ្រួសាររបស់លោក ត្រូវបានបញ្ឈប់ដោយរថយន្តចំនួន ៦ គ្រឿង ដោយមួយក្នុងចំណោមនោះជារបស់កងរាជអាវុធហត្ថ និងរថយន្ត ៥ គ្រឿងទៀត មិនស្គាល់ម៉ាក ដែលមានអាជ្ញាធរស្លៀកពាក់ស៊ីវិលនៅក្នុងរថយន្ត ហើយការចាប់ខ្លួននេះ ត្រូវបានធ្វើឡើងដោយមានមន្ត្រីកងរាជអាវុធហត្ថជាអ្នកដែលបានបង្ហាញឯកសារឱ្យ លោក ដារ៉ា មើលមុនពេលមានចាប់ខ្លួនរបស់លោក ។ ស្ទើរពេញ

មួយថ្ងៃក្រោយពីការចាប់ខ្លួនរបស់លោក ទាំងអាជ្ញាធរ និងមន្ត្រីអនុវត្តច្បាប់បានបដិសេធប្រាប់ពីទីតាំងឃុំខ្លួនរបស់លោក ដារ៉ា ដែលធ្វើឱ្យក្រុមគ្រួសារ និងមេធាវីមានការលំបាកក្នុងការជួប ក៏ដូចជាការជួយដល់លោក ។

មុនពេលចាប់ខ្លួន លោក ដារ៉ា រដ្ឋបាលខេត្តព្រៃវែងបានចេញសេចក្តីថ្លែងការណ៍មួយនៅលើបណ្តាញសង្គមហ្វេសប៊ុក ដោយធ្វើការចោទប្រកាន់ លោក ដារ៉ា ពីបទ "ចេតនាបំពុលសង្គមជាក់ស្តែង ឬបំភ្លើស" បន្ទាប់ពីលោក បានបង្ហោះរូបភាពពីរសន្លឹកពីសកម្មភាពជីកថ្មនៅ ភ្នំ ឈ្មោះបាភ្នំ ក្នុងខេត្តព្រៃវែង ។ រដ្ឋបាលខេត្តក៏បានអំពាវនាវឱ្យក្រសួងព័ត៌មានចាត់វិធានការតាមផ្លូវច្បាប់ចំពោះ លោក ដារ៉ា ផងដែរ ។

លោក ដារ៉ា គឺជាអ្នកសារព័ត៌ឈានមុខមួយរូប ដែលបានសរសេរអត្ថបទព័ត៌មានជាច្រើនក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដែលពុំមានអ្នកសារព័ត៌មានផ្សេងអាចធ្វើបាន ដូចជាទាក់ទងទៅនឹងអំពើពុករលួយ ការបំផ្លាញបរិស្ថាន និងការជួញដូរមនុស្សនៅទូទាំងប្រទេស ហើយក៏តែងតែជម្រុញឱ្យអាជ្ញាធរទទួលខុសត្រូវ និងផ្តល់យុត្តិធម៌ ។

ការងាររបស់លោក ដារ៉ា ត្រូវបានផ្សព្វផ្សាយដោយសារព័ត៌មានជាច្រើនដូចជា ខឺ ខេមបូឌាដេលី ភ្នំពេញប៉ុស្តិ៍ និងសម្លេងប្រជាធិបតេយ្យ (វីអូឌី) និងសារព័ត៌មានអន្តរជាតិជាច្រើនទៀត ។ កាលពីឆ្នាំមុន លោកបានក្លាយជាតំណាងឱ្យអ្នកដែលទទួលបានពានរង្វាន់ អ្នករាយការណ៍ពីការជួញដូរមនុស្ស ពីសហរដ្ឋអាមេរិក សម្រាប់ការងាររបស់លោកជុំវិញការចេញរបាយការណ៍ពីករណីជួញដូរមនុស្ស ។

យើងខ្ញុំសូមអំពាវនាវឱ្យរាជរដ្ឋាភិបាល ទម្លាក់ចោលរាល់បទចោទប្រកាន់ និងដោះលែងលោក ម៉ិច ដារ៉ា ពីពន្ធនាគារជាបន្ទាន់ ហើយបញ្ឈប់ការធ្វើទុក្ខបុកម្នេញ អ្នកសារព័ត៌មាន និងស្ថាប័នសារព័ត៌មានទាំងអស់ ។ ការចាប់ខ្លួនលោក ដារ៉ា គឺជាការព្យាយាមបំភិតបំភ័យ បំបិទសម្លេង លោក និងអ្នកសារព័ត៌មានដទៃទៀតនៅក្នុងប្រទេស ដែលគួរតែមានសេរីភាពផ្នែកសារព័ត៌មាន ៕

សេចក្តីថ្លែងការណ៍រួមនេះគាំទ្រដោយ៖

១. សហគមន៍ដីធ្លី ១៩៧ (កោះកុង)

២. Asian Forum for Human Rights and Development (FORUM-ASIA)

៣. Alliance of Independent Journalists (AJI) Indonesia
៤. សហគមន៍បឹងប្រាំ (បាត់ដំបង)
៥. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
៦. សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
៧. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
៨. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
៩. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ (CCIM)
១០. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
១១. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
១២. បណ្តាញយុវជនកម្ពុជា (CYN)
១៣. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
១៤. Centre for Independent Journalism (CIJ)
១៥. សហគមន៍ដីធ្លីជីខក្រោម (កោះកុង)
១៦. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
១៧. Communication and Media Promotion Organisation (CMPO)
១៨. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)
១៩. សហគមន៍ដក់ពរ (កំពង់ស្ពឺ)
២០. អង្គការសមធម៌កម្ពុជា (EC)
២១. Gerakan Media Merdeka (Geramm)
២២. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
២៣. Initiativ Kambodja (IK)
២៤. International Federation of Human Rights (FIDH)
២៥. សហគមន៍ជនជាតិដើមភាគតិចកួយឃុំប្រមេរុ ខេត្តព្រះវិហារ
២៦. សហគមន៍ជនជាតិដើមភាគតិចកួយ (ព្រះវិហារ)
២៧. សហគមន៍ដីធ្លីខេត្តប៉ៃលិន
២៨. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU)
២៩. LICADHO Canada
៣០. សហគមន៍ឡពាង (កំពង់ឆ្នាំង)
៣១. National Union of Journalists of the Philippines
៣២. Overseas Press Club of Cambodia (OPCC)
៣៣. សហគមន៍អូរបាត់មាន់ (ឧត្តរមានជ័យ)

៣៤. Prachatai (Thailand)
៣៥. សហគមន៍ព្រៃឈើពេជចង្វាល្អឆើត (កំពង់ឆ្នាំង)
៣៦. សហគមន៍រស្មីសាមគ្គី (កំពង់ស្ពឺ)
៣៧. អ្នកសារព័ត៌មានគ្មានព្រំដែន
៣៨. អង្គការសមាគមធាងត្នោត (ស.ធ.ត)
៣៩. សហគមន៍សាមគ្គីសង្កេពីរមានរិទ្ធិ (ព្រះវិហារ)
៤០. សហគមន៍ដីធ្លីស្រែប្រាំង (ត្បូងឃ្មុំ)
៤១. សហគមន៍ព្រៃឈើទេសចរណ៍ទឹកធ្លាក់ស្រែអំពិល (កំពង់ឆ្នាំង)
៤២. សហគមន៍ដីធ្លីតានី (សៀមរាប)
៤៣. Timor Leste Journalist Association (AJTL)
៤៤. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)
៤៥. សហគមន៍ត្រពាំងជោ (កំពង់ស្ពឺ)
៤៦. អង្គការតម្លាភាពកម្ពុជា (TIC)